ក្រសួងអប់រំ យុវជន និង កីឡា
សាកលវិទ្យាល័យខេមរៈ
KHEMARAK UNIVERSITY

មហាវិទ្យាល័យ វិទ្យាសាស្ត្រនយោបាយ និងទំនាក់ទំនងអន្តរជាតិ
Faculty of Political Science and International Relations

ឯកទេស៖ វិទ្យាសាស្ត្រនយោបាយ
Specialization: Political Science

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជា (ពីឆ្នាំ១៩៩៨ ដល់ ២០០៨)

# The Elections of Members of the National Assembly in the Kingdom of Cambodia (From 1998 to 2008)

និក្ខេបបទថ្នាក់បណ្ឌិត

បេក្ខជនបណ្ឌិត៖ ឯម សុផាត

សាស្ត្រាចារ្យណែនាំ៖ បណ្ឌិត ទេព ឈុនណារិទ្ធ
បណ្ឌិត ភា ម៉ាធុល

ភ្នំពេញ ២០១៥

ក្រសួងអប់រំ យុវជន និង កីឡា

សាកលវិទ្យាល័យខេមរៈ

KHEMARAK UNIVERSITY

មហាវិទ្យាល័យ វិទ្យាសាស្ត្រនយោបាយ និងទំនាក់ទំនងអន្តរជាតិ
Faculty of Political Science and International Relations

ឯកទេសៈ វិទ្យាសាស្ត្រនយោបាយ
Specialization: Political Science

# ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជា (ពីឆ្នាំ១៩៩៨ ដល់ ២០០៨)

# The Elections of Members of the National Assembly in the Kingdom of Cambodia (From 1998 to 2008)

ព្រះរាជាណាចក្រកម្ពុជា
បណ្ណាល័យ
លេខ 0011927
រាជបណ្ឌិត្យសភាកម្ពុជា

និក្ខេបបទថ្នាក់បណ្ឌិត

បេក្ខជនបណ្ឌិតៈ ឯម សុផាត

សាស្ត្រាចារ្យណែនាំៈ បណ្ឌិត ទេព ឈុនណារិទ្ធ
បណ្ឌិត ភា ម៉ាឆុល

ភ្នំពេញ ២០១៥

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១៤៧៣ អយក. ...

## លិខិតឧទ្ទេសនាម

**យោង:**-លិខិតលេខ ៧៥២ អយក ឧទនចុះថ្ងៃទី១១ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា។

-លិខិតលេខ០៥១/១៥ ស.ខ ចុះថ្ងៃទី ០២ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ សាកលវិទ្យាល័យខេមរៈ ។

លោក លោកស្រី ដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងជាគណៈកម្មការការពារនិក្ខេបបទ បញ្ចប់ការសិក្សា របស់និស្សិតថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យ ខេមរៈ។

| ល-រ | គោត្តនាម-នាម | សញ្ញាបត្រ | មុខងារ | ឯកទេស | តួនាទីគណៈកម្មការ |
|---|---|---|---|---|---|
| ១ | លោក ឆឹង សុខុល | បណ្ឌិត | គ្រូ | វិទ្យា.នយោបាយ | ប្រធាន |
| ២ | លោក សុខ ទូច | បណ្ឌិត | គ្រូ | វិទ្យា.នយោបាយ | គ្រូវាយតម្លៃទី១ |
| ៣ | លោក យង់ ពៅ | បណ្ឌិត | គ្រូ | វិទ្យា.នយោបាយ | គ្រូវាយតម្លៃទី២ |
| ៤ | លោក កា ម៉ាធុល | បណ្ឌិត | គ្រូ | វិទ្យា.នយោបាយ | គ្រូវាយតម្លៃទី៣ |
| ៥ | លោក តាន់ សុគន្ធា | បណ្ឌិត | គ្រូ | អក្សរសិល្ប៍ | សមាជិក |
| ៦ | លោក ទេព ឈុនណារិទ្ធ | បណ្ឌិត | គ្រូ | វិទ្យា.នយោបាយ | សមាជិក |
| ៧ | លោក រស់ ភ័រុជ | បណ្ឌិត | គ្រូ | វិទ្យា.នយោបាយ | លេខាកត់ត្រា |

-បេក្ខជនបណ្ឌិត: **ឯម សុផាត ភេទ ប្រុស**

-ប្រធានបទ: ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅព្រះរាជាណាចក្រ កម្ពុជា (ពីឆ្នាំ ១៩៩៨ដល់ ២០០៨)

-កាលបរិច្ឆេទ: ថ្ងៃទី២២ ខែ មីនា ឆ្នាំ២០១៥ ចាប់ពីម៉ោង ៨:០០

-ជំនាញ: វិទ្យាសាស្ត្រនយោបាយ

-គ្រូណែនាំ លោក ទេព ឈុនណារិទ្ធ និង លោក កា ម៉ាធុល

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែមីនា ឆ្នាំ២០១៥

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

យក់ ង៉ុយ

កន្លែងទទួល
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានឧត្តមសិក្សា
"ដើម្បីជ្រាប"
សាកលវិទ្យាល័យខេមរៈ
- សាមីជន
"ដើម្បីអនុវត្ត"
កាលប្បវត្តិ-ឯកសារ ន តវ

# មាតិកា

- ឧទ្ទិសស្នាដៃ....v
- សេចក្តីថ្លែងអំណរគុណ....vi
- អំណះអំណាង....vii
- ពាក្យប្រើជាអក្សរកាត់ ( ACRONYM )....viii
- មូលន័យសង្ខេប....x
- មូលន័យសង្ខេបជាភាសាអង់គ្លេស ( ABSTRACT )....xii
- សង្ខេបនិក្ខេបបទ....xiv
- សង្ខេបនិក្ខេបបទជាភាសាអង់គ្លេស ( SUMMARY )....xix
- អារម្ភកថា....xxiv

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ....១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ....២
៣. គោលបំណងនៃការស្រាវជ្រាវ....៣
៤. ដែនកំណត់នៃការស្រាវជ្រាវ....៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ....៤
៦. សារៈសំខាន់នៃការស្រាវជ្រាវ....៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ....៧

## ជំពូកទី ១
## វិធាននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

១. និយាមនៃបច្ចេកទេសបោះឆ្នោត....១០
១.១. ការបោះឆ្នោតក្នុងទម្រង់ដឹកនាំរដ្ឋសម័យបូរាណ....១០
១.២. ការបោះឆ្នោតក្នុងទម្រង់ដឹកនាំរដ្ឋសម័យទំនើប....១៣
១.៣. ការបោះឆ្នោតក្នុងរបបសង្គមប្រជាធិបតេយ្យ....១៦

១.៤. ការវិវត្តនៃបច្ចេកទេសបោះឆ្នោត.....២១
**២. ប្រព័ន្ធបោះឆ្នោតក្នុងសម័យទំនើប**.....២៥
២.១. ប្រព័ន្ធបោះឆ្នោត.....២៦
២.១.១. ក្រុមប្រព័ន្ធភាគច្រើនដោយប្រៀប/ដាច់ខាត.....២៦
២.១.២. ក្រុមប្រព័ន្ធសមាមាត្រ.....៣២
២.១.៣. ក្រុមប្រព័ន្ធចម្រុះ.....៣៦
២.១.៤. ក្រុមប្រព័ន្ធផ្សេងៗ.....៣៨
២.១.៥. បញ្ហាចំពោះប្រព័ន្ធបោះឆ្នោត.....៤១
២.២. វិធីបែងចែកអាសនៈ.....៤៣
២.២.១. វិធីបែងចែកអាសនៈសម្រាប់ក្រុមប្រព័ន្ធភាគច្រើនដោយប្រៀប/ដាច់ខាត.....៤៤
២.២.១. វិធីបែងចែកអាសនៈសម្រាប់ក្រុមប្រព័ន្ធសមាមាត្រ.....៤៥
២.២.៣.កម្រិតនៃភាពសមាមាត្រក្នុងការបែងចែកអាសនៈតាមក្រុមប្រព័ន្ធបោះឆ្នោត.....៤៨
២.២.៤. បញ្ហាចោទចំពោះរូបមន្តបែងចែកអាសនៈ.....៤៩
២.៣. លក្ខខណ្ឌបច្ចេកទេសបោះឆ្នោត.....៥០
**៣. លក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌**.....៥១
៣.១. ក្របខណ្ឌច្បាប់សម្រាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌.....៥២
៣.២. ស្ថាប័នគ្រប់គ្រងការបោះឆ្នោតដោយសេរីនិងយុត្តិធម៌.....៥៣
៣.៣. លក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌.....៥៥
៣.៤. ការប្រព្រឹត្តទៅនៃការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ តាមក្របខណ្ឌច្បាប់.....៥៨

## ជំពូកទី ២
## ការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**១. ស្ថានភាពទូទៅរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**.....៥៩
១.១. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប).....៥៩
១.២. បេសកកម្មនិងទស្សនវិស័យ គ.ជ.ប ក្នុងការគ្រប់គ្រងនិងរៀបចំការបោះឆ្នោត.....៦៣
១.៣. រចនាសម្ព័ន្ធនិងមន្ត្រីបុគ្គលិកនៃគ.ជ.បក្នុងការគ្រប់គ្រងនិងរៀបចំបោះឆ្នោត.....៦៥
១.៤. បទបញ្ជានិងរបៀបរបបបំពេញការងាររបស់ គ.ជ.ប.....៧៤
១.៥. ប្រតិទិននិងផែនការមេនៃការបោះឆ្នោត.....៧៨

៦.២. អ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិ........................................................................................១៩៤
៦.៣. សេចក្តីថ្លែងការណ៍របស់អង្គការសង្កេតការណ៍ និងគណបក្សនយោបាយ......................................១៩៦
**៧. ការដោះស្រាយបណ្តឹងចុងក្រោយនិងប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត...២០០**
៧.១. ការប្តឹងតវ៉ា និងដោះស្រាយបណ្តឹងទាក់ទងលទ្ធផលបណ្តោះអាសន្ននៅ គ.ជ.ប...........................២០១
៧.២. ការប្តឹងតវ៉ានិងដោះស្រាយបណ្តឹងទាក់ទងការបោះឆ្នោតនៅក្រុមប្រឹក្សាធម្មនុញ្ញ..........................២០២
៧.៣. ការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលផលិត និងប្រើប្រាស់ក្នុងការបោះឆ្នោត.................................២០៣
៧.៤. ការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ............................................២០៦

## ជំពូកទី ៣
## វិច័យការណ៍លើការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**១. ការវិភាគលើស្ថាប័នគ្រប់គ្រងការបោះឆ្នោត(គ.ជ.ប)នៃព្រះរាជាណាចក្រកម្ពុជា២១០**
**២. ការវិភាគលើការពិនិត្យបញ្ជីឈ្មោះ ការចុះឈ្មោះ និងរៀបចំបញ្ជីបោះឆ្នោត..........២១៩**
**៣. ការវិភាគលើការឃោសនាបោះឆ្នោត.........................................................................២៣០**
**៤. ការវិភាគលើការបោះឆ្នោត រាប់សន្លឹកឆ្នោតនិងបូកសរុបលទ្ធផលបោះឆ្នោត.......២៣៩**
**៥. កម្រិតនៃការទទួលស្គាល់លទ្ធផលផ្លូវការនៃការបោះឆ្នោត....................................២៥៩**

## សេចក្តីសន្និដ្ឋាន

**សន្និដ្ឋាន**..........................................................................................................................២៧៧
**អនុសាសន៍**..........................................................................................................................២៨០

**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# ឧទ្ទិសស្នាដៃ

ខ្ញុំបាទសូមឧទ្ទិសនិក្ខេបបទនេះថ្វាយនិងជូនចំពោះវីរក្សត្រ វីរបុរស វរជ្ជបុរស ជូនតា យុទ្ធជនយុទ្ធនារី អ្នកស្នេហាជាតិ និងប្រជាពលរដ្ឋខ្មែរគ្រប់ជំនាន់ ដែលបានធ្វើពលិកម្មដ៏ថ្លៃថ្លា ដើម្បីរួមចំណែកថែរក្សា ការពារទឹកដី កសាងសន្តិភាព ព្រមទាំងស្តារ កសាង និងអភិវឌ្ឍប្រទេសជាតិ ធានាបានអត្ថិភាព និងមានវិបុលភាពដូចសព្វថ្ងៃនេះ ។

ខ្ញុំបាទសូមឧទ្ទិសនិក្ខេបបទនេះជាកុសលជូនចំពោះវិញ្ញាណខ័ន្ធលោកឪពុក **ឯម តាន់** និងអ្នកម្តាយ **ខាច យ៉ាន** សូមលោកទាំងពីរបានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំបាទសូមឧទ្ទិសនិក្ខេបបទនេះជូនចំពោះអ្នកសិក្សាជំនាន់ក្រោយ អ្នកស្រាវជ្រាវ និងអ្នកបម្រើការងារក្នុងវិស័យពាក់ព័ន្ធ ដើម្បីប្រើប្រាស់ជាមូលដ្ឋានពិចារណាមួយផ្នែកនៅក្នុងការសិក្សាស្រាវជ្រាវ ស្វែងយល់ និងរកឃើញលទ្ធផលនៃការស្រាវជ្រាវថ្មីៗបន្ថែមទៀត ជាគុណប្រយោជន៍ដ៏ឧត្តុង្គឧត្តម ចំពោះការរៀបចំការបោះឆ្នោតដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមបែបប្រជាធិបតេយ្យនៅព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១៥

ដោយសេចក្តីគោរព

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ឯម សុផាត** សូមគោរពសម្តែងការដឹងគុណ និងកតញ្ញូតាធម៌ចំពោះលោកឪពុក **ឯម តាន់** និងអ្នកម្តាយ **ជាវ យ៉ាន** ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាង និងផ្តល់ព្រហ្មវិហារធម៌ ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ និងផ្តល់ដំបូន្មានល្អៗ ដើម្បីឱ្យកូនបានរស់រាននិងរៀនសូត្រចេះដឹងរហូតបានដល់កំរិតនេះដែលជាមូលដ្ឋានគ្រឹះនាំឱ្យរូបកូនមានសមត្ថភាពសមរម្យ និងគុណធម៌ល្អ រួមចំណែកលើកតម្កើងជីវភាព និងកិត្តិយសក្រុមគ្រួសារ និងចូលរួមស្តារ កសាង និងអភិវឌ្ឍសង្គមជាតិ ។

ខ្ញុំសូមអរគុណយ៉ាងធំធេងចំពោះភរិយា បុត្រាបុត្រី និងបងប្អូនប្រុសស្រីជាទីស្រឡាញ់ដែលតែងផ្តល់នូវក្តីស្រឡាញ់ និងការលើកទឹកចិត្តចំពោះខ្ញុំក្នុងការសិក្សាថ្នាក់បណ្ឌិតនេះ ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល គ្រប់ស្ថាប័នជាតិ សមាគម សង្គមស៊ីវិល និងប្រជាពលរដ្ឋខ្មែរ ដែលបានដឹកនាំ និងរួមចំណែកការពារ កសាងនិងអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ជាពិសេសលើវិស័យអប់រំជាតិ ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងធំធេងចំពោះឯកឧត្តម **អ៊ឹម សួស្តី** ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី មន្ត្រីបុគ្គលិកនៅទីស្តីការ គ.ជ.ប ដែលបានលើកទឹកចិត្តនិងគាំទ្រខ្ញុំក្នុងការសិក្សាស្រាវជ្រាវនិក្ខេបបទនេះ ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ លោកសាកលវិទ្យាធិការនៃសាកលវិទ្យាល័យខេមរៈ ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកនៅគ្រប់ការិយាល័យ គ្រប់ផ្នែកនៃសាកលវិទ្យាល័យខេមរៈដែលជានិច្ចកាលចាត់ចែង សម្របសម្រួលនិងគាំទ្រខ្ញុំក្នុងអំឡុងពេលនៃការសិក្សា និងការស្រាវជ្រាវនិក្ខេបបទនេះ ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រនិងជ្រាលជ្រៅចំពោះបណ្ឌិត **ខេព ឈុនណារិទ្ធ** និងបណ្ឌិត **ភា ម៉ាធុល** ដែលជាសាស្ត្រាចារ្យណែនាំផ្ទាល់ក្នុងការស្រាវជ្រាវនិក្ខេបបទនេះព្រមទាំងបានផ្តល់ការលើកទឹកចិត្ត ដំបូន្មានល្អ និងមតិណែនាំកែលំអប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ដើម្បីអាចឱ្យខ្ញុំសម្រេចបានជាស្ថាពរក្នុងការស្រាវជ្រាវនិក្ខេបបទនេះ ។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកសាស្ត្រាចារ្យបណ្ឌិត លោកបណ្ឌិតទាំងអស់ ក្នុងគណៈកម្មការវាយតម្លៃនិក្ខេបបទរបស់ខ្ញុំបាទ ដែលបានផ្តល់យោបល់ណែនាំនិងកែលម្អដ៏មានសារៈសំខាន់នាំឱ្យខ្ញុំបាទការពារបញ្ចប់និក្ខេបបទទទួលបានជោគជ័យ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១៥

# អំណះអំណាង

ខ្ញុំបាទ **ឯម សុផាត** សូមធានាអះអាងដោយកិត្តិយសថា ខ្លឹមសារនៃនិក្ខេបបទនេះគឺជាស្នាដៃដែលខ្ញុំបាទបានស្រាវជ្រាវនិងរៀបចំឡើងដោយផ្ទាល់ គ្មានពាក់ព័ន្ធនឹងនិក្ខេបបទរបស់អ្នកដទៃឡើយ ។

ខ្ញុំបាទសូមទទួលខុសត្រូវទាំងស្រុង ចំពោះលទ្ធផលនៃការស្រាវជ្រាវ ដែលខ្ញុំបាទបានលើកឡើងក្នុងនិក្ខេបបទស្តីពី " ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា(ពីឆ្នាំ១៩៩៨ដល់២០០៨) " (The Elections of Members of the National Assembly in the Kingdom of Cambodia, From 1998 to 2008) នេះថាជាលទ្ធផលនៃការស្រាវជ្រាវមួយថ្មីសុទ្ធសាធ ដែលពុំទាន់មានអ្នកណាម្នាក់យកទៅប្រើប្រាស់នៅក្នុងនិក្ខេបបទរបស់គេឡើយ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ២០១៥

ហត្ថលេខា

**ឯម សុផាត**

# ពាក្យប្រើជាអក្សរកាត់

## (ACRONYM)

៙៚៙៚

កបឃ/ស.......................................................................................ក្រុមប្រឹក្សាឃុំ សង្កាត់

គកប.......................................................................................គណៈកម្មការការិយាល័យបោះឆ្នោត

គករ.......................................................................................គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត

គខ/កប.......................................................................................គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត

គឃ/សប.......................................................................................គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត

គ.ជ.ប.......................................................................................គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

គធ/ខប.......................................................................................គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត

ច.ប.ឃ.ស.......................ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

ច.ប.ត.រ.......................ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ប.ន.ត.រ.......................បទបញ្ញានិងនីតិវិធីរបស់ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ប.ន.ព.ច.ធ.......................បទបញ្ញានិងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

លខ/កប.......................................................................................លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត

លធ/ខប.......................................................................................លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត

អ.ស.ប.......................................................................................អង្គការសហប្រជាជាតិ

AAEA.......................................................................................Association of Asian Election Authority

ACE..........ACE Electoral Knowledge Network ( Former of Administration and Cost of Elections )

AV.......................................................................................Alternative Vote

BBC.......................................................................................British Broadcasting Corporation

BC.......................................................................................Borda Count

BV.......................................................................................Block Vote

CAS.......................................................................................Center for Advanced Study

CDRI.......................................................................................Cambodia Development Resource Institute

COMFREL.......................................................................................Committee for Free and Fair Elections

COPCEL.......................................................................................Conflict Prevention in Cambodian Elections

EOM.......................................................................................Election Observation Mission

EU.......................................................................................European Union

FPTP.......................................................................................First Past The Post

IFES....................International Foundation for Election Systems
IIDEA....................International Institute for Democracy and Electoral Assistance
IPU....................Inter-Parliamentary Union
IRI....................International Republican Institute
LPR....................List Proportional Representation
LV....................Limited Vote
MMP....................Mixed Member Proportional
NDI....................National Democratic Institute for International Affairs
NEC....................National Election Committee
NGO....................Non Governmental Organization
NICFEC....................Neutral and Impartial Committee for Free and Fair Election
NIS....................National Institute of Statistics
OSCE....................Organization for Security and Co-operation in Europe
PBV....................Party Block Vote
PR....................Proportional Representation Systems
PS or Parallel....................Parallel System
SNTV....................Single Non-Transferable Vote
STV....................Single Transferable Vote
TRS....................Two-Round System
UNDP....................United Nations for Development Program
UNOPS....................United Nations Office for Project Services
UNTAC....................United Nations Transitional Authority in Cambodia
US....................The United States
USA....................The United States of America
USAID....................United States Agency for International Development
VRA I....................Voter Registration Audit I
VRA II....................Voter Registration Audit II
WHC....................World Heritage Committee

# មូលន័យសង្ខេប

ព្រះរាជាណាចក្រកម្ពុជាបានប្រកាន់យកនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ក្នុងទម្រង់គ្រប់គ្រងបែបរាជានិយមអាស្រ័យសភា គឺជាការជ្រើសរើសមួយដែលសមស្របនឹងនិន្នាការនៃការវិវត្តសកលលោក និងជានាឱ្យអំណាចគ្រប់គ្រងរដ្ឋមានអត្តិភាពស្របច្បាប់តាមរយៈការបោះឆ្នោត ។ ប៉ុន្តែ ការបោះឆ្នោតត្រូវតែបានអនុវត្តស្របតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ហើយត្រូវតែសមស្របនឹងកម្រិតយល់ដឹងរបស់ប្រជាពលរដ្ឋ ស្ថានភាពសេដ្ឋកិច្ចសង្គម និងក្របខណ្ឌច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ចាប់តាំងពីក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ២០០៨ អនុលោមទៅតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និងច្បាប់ពាក់ព័ន្ធ កម្ពុជាបានគ្រប់គ្រងនិងរៀបចំដោយខ្លួនឯងនូវការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាទៀងទាត់ ៣ លើកហើយ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានរៀបចំការបោះឆ្នោតឱ្យប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតម្លាភាព ហើយតែងបានកែលម្អដំណើរការបោះឆ្នោតនីមួយៗឱ្យស្របតាមក្របខណ្ឌច្បាប់ និងក្របខណ្ឌបច្ចេកទេស ។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ត្រូវបានសាធារណមតិជាតិ និងអន្តរជាតិភាគច្រើនវាយតម្លៃជាវិជ្ជមាន ។ ទន្ទឹមនឹងនេះ ការបោះឆ្នោតឆ្នាំ២០០៨ ក៏នៅមានចំណុចខ្វះខាត និងភាពអសកម្មមួយចំនួន ដែលកើតឡើងដោយកត្តាសត្យានុម័តផង និងកត្តាអត្តនោម័តផង ។

នៅក្រោយការបោះឆ្នោតម្តងៗ អង្គការសង្កេតការណ៍មួយចំនួនបានលើកឡើងរិះគន់ថា ការបោះឆ្នោតមិនទាន់មានលក្ខណៈសេរី និងយុត្តិធម៌ពិតប្រាកដនៅឡើយ ហើយគណបក្សនយោបាយខ្លះដែលមិនទទួលបានអាសនៈ ឬបានអាសនៈតិច តែងបានធ្វើការតវ៉ាជំទាស់នឹងលទ្ធផលនៃការបោះឆ្នោត ដែលបានបង្កឱ្យប្រទេសជាតិកើតមានភាពអាក់អួលនយោបាយ ឬការជាប់គាំងនយោបាយក្នុងរយៈពេលវែង ឬខ្លី ។

ការជម្រុញការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅព្រះរាជាណាចក្រកម្ពុជានាអនាគត ឱ្យប្រព្រឹត្តទៅកាន់តែប្រសើរឡើងគឺជាការទទួលបន្ទុករួមគ្នារបស់ គ.ជ.ប ស្ថាប័នមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធ ព្រមទាំងប្រជាពលរដ្ឋអ្នកបោះឆ្នោត ។ ការកំណត់ទស្សនវិស័យនិងការដាក់ចេញវិធាននានា ដើម្បីកែលម្អទាំងក្របខណ្ឌច្បាប់និងក្របខណ្ឌបច្ចេកទេស ទាំងការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រង និងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនាអនាគតគឺជាតម្រូវការចាំបាច់ ។

ការកែលម្អលក្ខខណ្ឌសត្យានុម័តនានា និងការធ្វើកំណែទម្រង់រដ្ឋបាលរបស់ គ.ជ.ប ដោយផ្ទាល់គឺជាគោលដៅក្នុងការពង្រឹង គ.ជ.ប ។ ការពិចារណាដាក់បញ្ចូលបទប្បញ្ញត្តិអំពីស្ថាប័ន គ.ជ.ប ទៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ ការរៀបចំឱ្យមានច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ គ.ជ.ប និងការដាក់បញ្ចូលគម្រោងថវិកា គ.ជ.ប សម្រាប់ការងារបោះឆ្នោតទៅក្នុងច្បាប់ថវិកាជាតិ គឺជាគន្លឹះក្នុងការដោះស្រាយរាល់បញ្ហាសត្យានុម័ត ។ ការធ្វើកំណែទម្រង់រដ្ឋបាលនៃ គ.ជ.ប ឱ្យស្របតាមបាវចនារបស់ខ្លួន និងស្របតាមគោលការណ៍ជាមូលដ្ឋានសម្រាប់គំរូស្ថាប័នគ្រប់គ្រងការបោះឆ្នោតគឺជួយ គ.ជ.ប ឱ្យក្លាយជាស្ថាប័នគ្រប់គ្រងការបោះឆ្នោតឯករាជ្យ ។

ការចុះឈ្មោះបោះឆ្នោត និងរៀបចំបញ្ជីបោះឆ្នោត ដោយប្រើប្រព័ន្ធបញ្ជីបោះឆ្នោតអចិន្ត្រៃយ៍ត្រូវបានអនុវត្តនិងកែលម្អជាបន្តបន្ទាប់ ។ ការចង់ត្រឡប់ទៅប្រើប្រព័ន្ធបញ្ជីបោះឆ្នោតក្នុងរយៈពេលមានកំណត់ដូចពេលបោះឆ្នោតរៀបចំដោយអ៊ុនតាក់ ឬការចង់ផ្លាស់ប្តូរទៅប្រើប្រព័ន្ធបញ្ជីបោះឆ្នោតតាមអត្រានុកូលដ្ឋានដែលសព្វថ្ងៃ

មិនទាន់រឹងមាំនៅឡើយ គឺពិតជាមិនអាចទៅរួចនោះទេ ។ យ៉ាងណាក្តី ការកែលម្អក្របខណ្ឌច្បាប់និងក្របខណ្ឌបច្ចេកទេសនិងការពង្រឹងការអនុវត្តប្រព័ន្ធចុះឈ្មោះបោះឆ្នោតកំពុងនៅជាធរមាន គឺជាវិធានអាទិភាពចំពោះមុខនិងអនាគតដ៏ខ្លី ដើម្បីធ្វើឱ្យបញ្ជីបោះឆ្នោតកាន់តែមានគុណភាព ។

នៅក្នុងការឃោសនាបោះឆ្នោត គណបក្ស និងបេក្ខជនមានឱកាសច្រើន ក្នុងការផ្សព្វផ្សាយខ្លឹមសារឃោសនាឥតគិតថ្លៃ ផ្អែកតាមគោលការណ៍ស្មើភាព និងគោលការណ៍សមធម៌ ក្រៅពីនេះនៅបានធ្វើសកម្មភាពឃោសនាតាមគោលការណ៍ជួលប្រព័ន្ធផ្សព្វផ្សាយ និងតាមរូបភាពនិងមធ្យោបាយផ្សេងៗ ដោយសេរីនិងទូលំទូលាយដែលត្រូវរ៉ាប់រងចំណាយដោយសាមីគណបក្សនិងបេក្ខជនផ្ទាល់។ ផ្អែកលើស្ថានភាពសេដ្ឋកិច្ចនិងសង្គមកម្ពុជា លទ្ធភាពដែលរដ្ឋនឹងត្រូវផ្គត់ផ្គង់ថវិកាជូនគណបក្សសម្រាប់ការឃោសនាបោះឆ្នោត ពិតជាពុំអាចធ្វើបានក្នុងអនាគតដ៏ខ្លីនោះឡើយ ប៉ុន្តែកំណែទម្រង់ច្បាប់ស្តីពីបញ្ហានេះគួរតែបានពិចារណានាអនាគតសមស្រប ។

ការគោរពយ៉ាងម៉ឺងម៉ាត់នូវបទប្បញ្ញត្តិ និងរាល់គោលការណ៍ស្តីពីការឃោសនាបោះឆ្នោតដែលចែងក្នុង ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌សម្រាប់គណបក្ស បេក្ខជននិងតំណាងគណបក្ស ព្រមទាំងគោលការណ៍ និងក្រមសីលធម៌សម្រាប់ភាគីពាក់ព័ន្ធ គឺជាគន្លឹះក្នុងការកាត់បន្ថយវិវាទក្នុងអំឡុងពេលឃោសនាបោះឆ្នោត និងជាការធានាឱ្យការឃោសនាបោះឆ្នោតប្រព្រឹត្តទៅដោយរលូន ។

កិច្ចប្រតិបត្តិការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតត្រូវបានកែលម្អជាបន្តបន្ទាប់ ប៉ុន្តែក៏នៅមានភាពអសកម្មនិងចំណុចខ្វះខាតខាងបច្ចេកទេសនៅផ្នែកការងារខ្លះនិងតំបន់បោះឆ្នោតខ្លះ ដែលទាមទារពុះពារកែលម្អ ដើម្បីជម្រុញឱ្យការរៀបចំការបោះឆ្នោតទៅអនាគត ឆ្លើយតបបានទៅនឹងលក្ខណៈវិនិច្ឆ័យនិងនិយាមបច្ចេកទេសសម្រាប់ការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ ។ នាអនាគត ការងារចាំបាច់ត្រូវពង្រឹងបន្ថែមមានដូចជា ការបណ្តុះបណ្តាលមន្ត្រីបោះឆ្នោត តំណាងគណបក្ស និងតំណាងអង្គការសង្កេតការណ៍រួមជាមួយគ្នានៅ គ.ជ.ប និង គខ/កប ការអប់រំសាធារណជននិងផ្សព្វផ្សាយព័ត៌មានសាធារណៈអំពីការបោះឆ្នោត ការបណ្តុះបណ្តាលតំណាងគណបក្ស និងអ្នកសង្កេតការណ៍អំពីការសង្កេតការណ៍បោះឆ្នោតបែបវិជ្ជាជីវៈ និងការពង្រឹងគុណភាពក្នុងការបណ្តុះបណ្តាល គខ/កប គឃ/សប និងតំណាងគណបក្សអំពីនីតិវិធីនៃការដាក់/ទទួលនិងដោះស្រាយបណ្តឹងតវ៉ា ឬ/និងជំទាស់ទាក់ទងនឹងការបោះឆ្នោតជាដើម ។

ចំពោះការតវ៉ាជំទាស់នឹងលទ្ធផលនៃការបោះឆ្នោត ដែលបានបង្កឱ្យមានការជាប់គាំងនយោបាយ ២ លើក (ឆ្នាំ១៩៩៨ និងឆ្នាំ២០០៣) នោះគឺបណ្តាលមកពីមូលហេតុសំខាន់ពីរ ៖ ទីមួយ ការដែលគណបក្សទទួលបានអាសនៈតិចបានលើកយកចំណុចខ្វះខាតមួយចំនួន នៅក្នុងការរៀបចំការបោះឆ្នោតធ្វើជាហេតុផលនយោបាយ និងទីពីរ ការប្រើប្រព័ន្ធ ២/៣ សម្រាប់ការអនុម័តជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងការផ្តល់សេចក្តីទុកចិត្តលើសមាសភាពរាជរដ្ឋាភិបាល ក្នុងស្ថានភាពនៅខ្វះចន្លោះក្របខណ្ឌច្បាប់ស្តីពី ការកំណត់លក្ខខណ្ឌនៃការចែករំលែកអំណាចគ្នារវាងគណបក្សឈ្នះឆ្នោតនៅឡើយ ។ ដោយសារមានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនាឆ្នាំ២០០៦ ដែលតម្រូវឱ្យប្រើប្រព័ន្ធមតិភាគច្រើនដាច់ខាត (៥០+១) ជំនួសប្រព័ន្ធ ២/៣ បន្ទាប់ពីការបោះឆ្នោតឆ្នាំ២០០៨ និងលើកក្រោយៗ ព្រះរាជាណាចក្រកម្ពុជានឹងមិនមានការជាប់គាំងនយោបាយដូចពេលមុនទៀតឡើយ ។

## ABSTRACT

The Kingdom of Cambodia has being maintained the policy of liberal pluralism democracy in the governing form of parliamentary monarchy which is a suitable option to the tendency of universal progress and to ensure the state governing power legally exists through the election. However, the election shall be implemented according to the criteria for the free and fair election and must be suitable to the knowledge-base of the peoples, the socio-economic situation and the legal frameworks of the Kingdom of Cambodia.

In according to the Law on the Election of Members of the National Assembly and its amendments (LEMNA) and other relevant Laws, after the 1993 election up to 2008, Cambodia had managed and organized regularly by itself 3 elections of the national assembly members. The National Election Committee (NEC) has organized the elections in a free, accurate, just and transparent manner, and has always promoted and ameliorated every election process to be complied with the legal and technical frameworks.

The 2008 election of the national assembly members were positively evaluated by most of national and international opinions. Meanwhile, it remained some shortage and inactivity happened by both objective and subjective reasons.

After every election took place, some observation organizations launched their critics that the election did not run with fully free and truly just manner yet; and also, some political parties who did not gain any seat and/or gained least seats always claimed against the election results, which led the country into political unrest and/or political deadlock for a long or short times.

In the Kingdom of Cambodia, the promotion of the well organized election of the national assembly members in the future is the common responsibility of all parties such as the NEC, the competent organs/ministries, all stakeholders and citizens entitle as voters, as well. Hence, the defining of visions and the setting forth of measures in order to further ameliorating at all fields of legal and technical frameworks and of concrete implementation in managing and organizing the future election of the national assembly members are necessary indeed.

The improvement of all objective conditions and the reform of public administration of the NEC itself is the goal to strengthen the NEC. The consideration of amending the provisions related to the NEC into the Constitution, the creation of the organic law on organization and functioning of the NEC and the inclusion of the NEC estimated budget for the elections into the Law on national budget are the key points in solving of all above objective issues. The reform of public administration of the NEC to meet its motto and to be complied with the fundamental principles for the sample of Election Management Body will promote the NEC becoming as an independent Election Management Body.

The voter registration and the voter list formation using the continuous voter registry system were executed and improved continuously. The attempt to return to the periodic voter registry system using during the election organized by UNTAC that could not be controlled or the wish of changing to use the civil registry voter list system, where the current civil registry is not good enough, will not be

realized in the near future. However, in the forthcoming period and the near future, the improvement of legal and technical frameworks and the reinforcement of implementation of the existing voter registration system are the priority measures in order to create the better quality voter list.

During the electoral campaign, political parties and candidates got many opportunities in disseminating, free of charge, the essences of campaign through many means of equal and equity principles managed by the NEC; besides, they also took their campaign actions through principle for renting of broadcasting hours from private television and/or radio stations and through other means and figures freely and widespread, which were covered by political parties and candidates themselves. According to current socio-economic situation in Cambodia, the possibility of providing of state funding to the political parties spending during electoral campaign, could not be realized yet in the near future; however, it should be taken into consideration for the legal reform on the relevant issue at a convenient time in the future.

The strict respecting and executing of all provisions and principles related to electoral campaign stated in LEMNA, the regulations and procedures, the code of conduct for political parties, candidates and party agents and other principles and code of conduct for relevant stakeholders will be the keys in reducing any conflicts happening during electoral campaign and will ensure the electoral campaign practicing with smooth.

The operations of polling, ballot counting and consolidation of election results were continuously enhanced. However, there were still some inactivity and shortage on technical fields at a few working sector and a few polling division, which were needed to severely correct in order to promote the organizing of future elections to meet the criteria and technical norm for the free and fair election.

In the future, some work fields must be improved and reinforced are as the following : the joint training at the NEC and PECs between electoral officials and representatives of political parties and monitoring organizations, the public education and the public information about the election, the training of party agents and observers about knowledge on professional electoral monitoring, and the strengthening of the training quality of the PECs, the CECs and the representatives of political parties about procedures on the submission, receipt and resolution of the complaints and/or appeals concerning with election and so on.

For the past claiming against the election results, which creating two times of political deadlocks after the 1998 and 2003 elections, happened by two main reasons; they were, firstly, the political parties gaining least seats used some shortage during the organizing of each election as wording as tense political reasons, and secondly, the using of majority of 2/3 vote system for the adoptions of Leaders of the National Assembly and for the vote of confidence on composition of the Royal Government at the circumstance of lacking of legal framework on determination about sharing power conditions amongst parties winning election yet. Due to the 2006 amendment of the Constitution that allows to use the absolute majority vote ( 50+1 ) system instead of the previous majority of 2/3 vote system, expecting that at the end of 2008 election and any election later, the Kingdom of Cambodia will meet no more political deadlocks as seen during after the previous elections.